# ៣. ធីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខា.ប្រមាញ់ និង នេសាទ

## ប្រកាស

ប្រកាសលេខ ៥៣៧ ប្រក-កសក ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ១៩៩៤

ស្តីពី

**ការបង្កើតឯកសណ្ឋាន និង សញ្ញាសំគាល់**

**របស់អគ្គការ រុក្ខា-ប្រមាញ់**

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញក្រឹត្យ-ច្បាប់លេខ ៣៥ ក្រ.ច ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៨៨ ស្តីពីការ គ្រប់គ្រងវិស័យព្រៃឈើ

-បានឃើញអនុក្រឹត្យលេខ ១៨អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ១៩៨៨ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំង របស់ក្រសួងកសិកម្ម

-បានឃើញប្រកាសរបស់ក្រសួងកសិកម្ម លេខ ០០៧២ ប្រក.កសក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ១៩៨៩ ស្តីពីការបង្កើតឯកសណ្ឋាននិង សញ្ញាសំគាល់របស់ កម្មាភិបាល បុគ្គលិក រុក្ខា-ប្រមាញ់

-បានឃើញប្រកាសរបស់ក្រសួងកសិកម្ម លេខ ៥០៨ ប្រក.កសក ចុះថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ ១៩៩២ ស្ដីពីការប្ដូរពណ៌ឯកសណ្ឋាន និង សញ្ញាសំគាល់របស់អង្គការ រុក្ខា- ប្រមាញ់

-តាមសំណើ របស់ ប្រធាននាយកដ្ឋាន រុក្ខា- ប្រមាញ់

**សំរេច**

**មាត្រា ១ :** អនុញ្ញាតឲ្យអង្គការរុក្ខា-ប្រមាញ់បង្កើតឯកណ្ឋាន និង សញ្ញាសំគាល់ដូចមានកំណត់ក្នុងឯកសារឧបសម្ព័ន្ធភ្ជាប់ជាមួយ សំរាប់មន្ត្រីរុក្ខា-ប្រមាញ់ដើម្បីប្រើប្រាស់ក្នុងពេលប្រតិបត្តិការ និង ពិធីផ្សេង ៗ ។

**មាត្រា ២ :** ក្នុងពេលប្រតិបត្តិការ មន្ត្រីរុក្ខា-ប្រមាញ់ត្រូវស្លៀកពាក់ឯកសណ្ឋានពាក់សញ្ញាសំគាល់ និង ត្រូវមានលិខិតបញ្ជាបេសកកម្មជាប់តាមខ្លួនផង ។

-ក្នុងពិធីផ្សេងៗ បើចាំបាច់ ត្រូវស្លៀកពាក់ឯកសណ្ឋាន និង ពាក់សញ្ញាសំគាល់ដែរ ។

**មាត្រា ៣ :** ជនក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាន និង ពាក់សញ្ញាសំគាល់ដូចមានចែងក្នុងមាត្រា១ ដើម្បីបន្លំធ្វើជាមន្ត្រីរុក្ខា-ប្រមាញ់ ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៤ :** ប្រកាសលេខ ០០៧២ ប្រក.កសក ចុះថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ ១៩៨៩ និង ប្រកាសលេខ ៥០៨ ប្រក.កសក ចុះថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ១៩៩២ ព្រមទាំងបទបញ្ញត្តិផ្សេងៗទៀតដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៥ :** ប្រធានមន្ទីរក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និង នេសាទ ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការស្ថិតិ ប្រធាននាយកដ្ឋានចាត់តាំង ប្រធានគណៈកម្មាធិការត្រួតពិនិត្យក្រសួង ប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ ប្រធានមន្ទីរកសិកម្មខេត្ត ក្រុង និង ប្រធានការិយាល័យរុក្ខា-ប្រមាញ់ខេត្ត ក្រុង ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តប្រកាសនេះ ។

មាត្រា ៦ :ប្រកាសនេះ មានអនុភាពគតិយុត្តិចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ជ.រដ្ឋមន្ត្រីក្រសួងកសិកម្ម

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ឈា សុខ

* * *

# ឯកសារឧបសម្ព័ន្ធ

# ស្តីពី

# ឯកសណ្ឋាន និង សញ្ញាសំគាល់

# របស់អង្គការរុក្ខា-ប្រមាញ់

I. ឯកសណ្ឋាន

សំរាប់ស្លៀកពាក់ក្នុងពេលចុះបង្ក្រាបបទ ល្មើសផលព្រៃឈើទូទាំងប្រទេស និង ក្នុងពិធីផ្សេង ៗ ។ ខោ អាវធ្វើពីក្រណាត់ស៊ីម្លី ពណ៌កាគី " សាច់ឈើ " ។

រូបភាព និង ម៉ូដ :

-អាវដៃវែង ឬ ខ្លី កឧប ផ្ទេរឧប ប៉ូលស្មា មានហោប៉ៅលើពីរដេរប៉ះដោយបត់ផ្នត់ចំកណ្តាល និង មានគំរបរាងស្លឹកពោធិ កាត់ស្រុងវែងសំរាប់ដាក់ក្នុងខោ ។

-ខោជើងវែង ចង្កេះត ថ្នេរបង្កប់ ជីពខាងមុខពីរ មានហោប៉ៅ៤ "ហោប៉ៅ២ខាងក្រោយដេរបង្កប់មានគំរបរាងស្លឹកពោធិ និង ហោប៉ៅ២ទៀតនៅចំហៀងដេរបង្កប់តាមថ្នេរ "។

-ស្បែកជើងកខ្លី ពណ៌ខ្មៅ និង ស្រោមជើងពណ៌ខ្មៅ ។

-ខ្សែក្រវាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវាត់ពណ៌មាស ។

ចំពោះមន្ត្រីនារី ស្លៀកពាក់សំពត់ហ្សីបក្រោមជង្គង់ ឆែកក្រោយ ឬ ខោ និង អាវម៉ូតដូចខាងលើ តែអាវមានជីពចង្កេះ ។

II . ផ្លាកសញ្ញាសំគាល់ :

ផ្លាកសញ្ញាសំគាល់របស់អង្គការរុក្ខា-ប្រមាញ់កំណត់សំគាល់ ដូចខាងក្រោម សំរាប់ពាក់លើមួក លើចុងកអាវឆ្វេង ស្តាំនិងសំរាប់ព្យួរលើហោប៉ៅអាវឆ្វេង :

ក- រូបព្រះសង្ហា :

រូបព្រះសង្ហាយកតាមសម័យសង្គមរាស្ត្រនិយម ធ្វើពីលោហធាតុពណ៌មាស សំរាប់ពាក់លើមួកកាស្កេត ដែលមានទំហំកំពស់ ៧,៨ស.ម ទទឹង ៦,៨ស.ម និង សំរាប់ពាក់លើមួកហាមធំ មួកកេពី និង បេរ៉េ កំពស់ ៥ស.ម ទទឹង ៤,៣ស.ម ។

ខ- ផ្លាកសញ្ញាសំរាប់ពាក់លើចុងកអាវឆ្វេង ស្តាំ :

ដោយកំណត់យកទងស្លឹកអំបូរណ៍ឡៅហ្គីមីណើ ដែលមានផាង និង សន្លឹកចំនួន ១៣ ពណ៌មាស ទំហំបណ្តោយ ៤,៣ស.ម ទទឹង២,៣ស.ម។

គ- ផ្លាកសញ្ញាសំរាប់ព្យួរលើហោប៉ៅអាវឆ្វេង :

តួផ្លាកសញ្ញាធ្វើពីលោហធាតុរាងសំប៉ែត ភ្ជាប់ដោយបន្ទះស្បែកសំរាប់ព្យួរលើហោប៉ៅអាវឆ្វេង :

. ទំហំកំពស់ ៤ . ២ស.ម

. ទំហំទទឹង ៣ . ៤ស.ម

. ផ្ទៃខាងក្នុងតួសញ្ញាពណ៌ផ្ទៃមេឃ

* ខណ្ឌខាងក្រៅ " ផ្នែកខាងលើ "

ក្បាច់ភ្ញីទេសឱនពណ៌មាសផុសឡើងអមសងខាងតួមកុដ

. មកុដពណ៌មាសចំរុះដោយពណ៌ក្រហមក្រម៉ៅ

. ផ្លត់សំពត់ពណ៌មាសចំរុះពណ៌ក្រហមក្រម៉ៅទ្រមកុដ

* ខណ្ឌខាងក្រៅ " ផ្នែកខាងក្រោម "

ពណ៌បៃតងចាស់រំលេចដោយតួអក្សរ "រុក្ខាកម្ពុជា"ពណ៌មាស

* ខណ្ឌខាងក្រៅ " ឆាំងសងខាង "

ទិដ្ឋភាពជាសំពត់មានផ្លត់បីថ្នាក់ពណ៌ក្រហមក្រម៉ៅ និង ចុងជាយនិមួយ ៗ រំលេចពណ៌មាស

* នៅចំពាក់កណ្តាលផ្លាក :

រូបដើមឈើពណ៌មាស និង ស្លឹកឈើបីត្រសុំពណ៌បៃតងចាស់ ។ នៅប៉ែកខាងគល់ដើមឈើមានញញួរគ្រាដែកពីរពណ៌មាស ដោយមានដងពីរខ្វែងគ្នា ។

* នៅសងខាង និង ក្រោមដើមឈើ កណ្តាលផ្លាក :

មានផ្កាចំរុះបែកជាវង្វង់ក្បាច់ភ្ញីស្លឹកកន្ទួតពណ៌មាសពីរ មានទំរង់ជាស្នែងក្របី ។

III. សញ្ញាមួក :

១. មួកការស្កុត ឬ មួកកេពី :

ធ្វើពីក្រណាត់ពណ៌ដូចខោ ដែលផ្នែកខាងមុខ លើកណ្តាប់វណ្ណ មានភ្ជាប់រូបព្រះសង្ហាពណ៌មាសទំហំកំពស់ ៧ , ៨ស.ម ទទឹង ៦ ,៨ស.ម ប៉ែកខាងក្រោមនៃជើងមួក និង ក្រោមព្រះសង្ហា មានកណ្តាប់វណ្ណ

ធ្វើពីក្រណាត់ខ្សែន ពណ៌ត្រែអ៊ីព័ទ្ធជុំវិញ ។ ខាងក្រោមកណ្ដាប់វណ្ណ ប៉ែកខាងមុខមានក្បាំងមុខពណ៌ខ្មៅ ។

**មួកការ៉េស្កត ឬ មួករកពី ត្រូវបានកំណត់បែងចែកជាបួនប្រភេទ :**

-ផ្នែកខាងមុខ ក្រោមកណ្ដាប់វណ្ណដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរមានភ្ជាប់ដោយឡេវរូបព្រះសង្ហាពណ៌មាស ។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសឱនពណ៌មាសទម្រង់ ស្នែងក្របីដល់ជើងមួកសំរាប់សំគាល់មន្ត្រីថ្នាក់នាយកដ្ឋានឡើងទៅ ។

-ផ្នែកខាងមុខ ក្រោមកណ្ដាប់វណ្ណដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវរូបព្រះសង្ហាពណ៌មាស ។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសឱនពណ៌មាសទម្រង់ស្នែងក្របី ដោយចុងសងខាងទុកចន្លោះ ៨ ស.ម ពីជើងមួក សំរាប់សំគាល់មន្ត្រីថ្នាក់ការិយាល័យ ថ្នាក់ឧត្តម និង មន្ត្រីថ្នាក់មធ្យម ដែលបានបំពេញការងារល្អអស់រយៈពេល ១០ ឆ្នាំ បន្ទាប់ពីបានតែងតាំងក្នុងក្រខ័ណ្ឌពេញសិទ្ធិ ដោយមានការសំរេចពីប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ ។

-ផ្នែកខាងមុខ ក្រោមកណ្ដាប់វណ្ណដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវរូបព្រះសង្ហាពណ៌មាស និងនៅលើក្បាំងមួកមានវណ្ណទំហំ ៥ ម.ម ពណ៌មាស ព័ទ្ធវង់ដល់ជើងមួកសំរាប់សំគាល់មន្ត្រី ថ្នាក់ក្រោមការិយាល័យ ថ្នាក់មធ្យម និង មន្ត្រីថ្នាក់បឋម ដែលបានបំពេញការងារល្អអស់រយៈពេល ១០ ឆ្នាំ បន្ទាប់ពីបានតែងតាំងក្នុងក្របខ័ណ្ឌពេញសិទ្ធិដោយ មានការសំរេចពីប្រធាននាយកដ្ឋាន រុក្ខា-ប្រមាញ់ ។

-ផ្នែកខាងមុខ ក្រោមកណ្ដាប់វណ្ណដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយ

ឡេវរូបព្រះសង្ហាពណ៌មាស សំរាប់សំគាល់មន្ត្រីរុក្ខា-ប្រមាញ់ថ្នាក់បឋម និង ថ្នាក់ប្រហាក់ប្រហែល ។

២- មួករបេរ៉េ :

មួកបេរ៉េធ្វើពីក្រណាត់ខៀវ ពណ៌ត្រែអ៊ី ប៉ែកខាងមុខមានភ្ជាប់រូបព្រះសង្ហាពណ៌មាស និង ប៉ែកខាងក្រោយមានកន្ទុយខ្សែពីរពណ៌ខ្មៅ ។

ជ.រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខា-ប្រមាញ់និងនេសាទ

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឈា សុខ

* * *

# ៨- ពិស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

## ប្រកាស

*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ១១ ឆ្នាំ ១៩៩៤*

## ប្រកាសលេខ ១១៨/៩៤ ពម-ប្រ.ក

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ វរ័ន្ម ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ ១១ ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ កម្ពុជា ។